# សេចក្តីជូនដំណឹងអ្នកសារព័ត៌មាន

**ប្រធានបទ៖** "កិច្ចប្រជុំទ្វេភាគី និងពិធីចុះអនុស្សរណៈរវាងកម្ពុជា និងបង់ក្លាដេស លើការទិញអង្ករចំនួន ១ លានតោន ក្នុងរយៈពេល ៥ឆ្នាំ"

**អ្នកចូលរួម៖** រដ្ឋមន្ត្រីពាណិជ្ជកម្មរបស់កម្ពុជា, រដ្ឋមន្ត្រីស្បៀងអាហាររបស់បង់ក្លាដេស, គណៈប្រតិភូមន្ត្រីជាន់ខ្ពស់ប្រទេសកម្ពុជា និងប្រទេសបង់ក្លាដេស។

**ទីកន្លែង៖** សាលប្រជុំអង្គរវត្ត នៃក្រសួងពាណិជ្ជកម្ម (ជាន់ទី២)

**កាលបរិច្ឆេទ៖** ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ ម៉ោង ២:៣០រសៀល (កម្មវិធីលម្អិត សូមមើលរបៀបវារៈ)

---

***គោរពជូនលោកអ្នកសារព័ត៌មានជាទីរាប់អាន!***

យើងខ្ញុំសូមគោរពអញ្ជើញលោកអ្នក ចូលរួមយកព័ត៌មាននៅក្នុងព្រឹត្តិការណ៍ខាងលើ ដែលមានគោលបំណងបើកច្រក និងពង្រីកការនាំចេញអង្ករកម្ពុជា ទៅកាន់ទីផ្សារក្រៅប្រទេស សំដៅត្រៀមទប់ទល់បញ្ហាកើនឡើងនៃបរិមាណស្រូវនៅកម្ពុជា ក្នុងពេលបច្ចុប្បន្ន ក៏ដូចជាការចូលមកដល់នៃរដូវប្រមូលផលស្រូវនាពេលខាងមុខ។

ជំនួបប្រជុំទ្វេភាគី និងពិធីចុះអនុស្សរណៈរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស នឹងនាំមកនូវអត្ថប្រយោជន៍ធំធេងចំពោះវិស័យស្រូវ-អង្ករកម្ពុជា ដោយក្នុងនោះរដ្ឋាភិបាលបង់ក្លាដេស នឹងធ្វើការទិញអង្ករគ្រប់ប្រភេទពីរដ្ឋាភិបាលកម្ពុជាចំនួន ១លានតោន ក្នុងរយៈពេល ៥ឆ្នាំ ចាប់ពីឆ្នាំ ២០១៧នេះតទៅ។

អនុស្សរណៈនេះ នឹងគ្របដណ្តប់លើប្រតិបត្តិការទិញ/លក់អង្ករទាំងអស់ ហើយនឹងត្រូវអនុវត្តន៍ដោយក្រុមហ៊ុនហ្គ្រីនត្រេដ (GTC) ដែលជាក្រុមហ៊ុនសហគ្រាសសាធារណៈ ចំណុះឲ្យក្រសួងពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា ជាមួយអគ្គនាយកដ្ឋានម្ហូបអាហារ (DGF) ដែលជាក្រុមហ៊ុនសហគ្រាសសាធារណៈ ចំណុះឲ្យក្រសួងស្បៀងអាហារ នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស។

នៅក្នុងព្រឹត្តិការណ៍ដ៏មានសារៈសំខាន់នេះ ក៏មានរៀបចំជាសន្និសីទសារព័ត៌មាន សម្រាប់អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ លើកជាសំណួរផ្សេងៗ ទៅកាន់មន្ត្រីជាន់ខ្ពស់នៃប្រទេសទាំងពីរផងដែរ។

អាស្រ័យហេតុនេះ ក្រសួងពាណិជ្ជកម្ម សង្ឃឹមមុតមាំថា លោកអ្នកនឹងលៃលកពេលវេលា ចូលរួមយកព័ត៌មាននៅក្នុងព្រឹត្តិការណ៍ខាងលើ ដើម្បីផ្សព្វផ្សាយលទ្ធផលជូនសាធារណៈជន។ សម្រាប់ព័ត៌មាន ឬ ឯកសារបន្ថែម សូមទំនាក់ទំនង **លោក ចាន់ សុខទី** អគ្គនាយកក្រុមហ៊ុនហ្គ្រីនត្រេដ តាមរយៈទូរស័ព្ទលេខ 012 222 797 ឬ អ៊ីម៉ែល chansokty9@gmail.com ។ **សូមអរគុណ!**

**កិច្ចប្រជុំទ្វេភាគី**
**និងពិធីចុះអនុស្សរណៈនៃការយោគយល់គ្នា**
**រវាង**
**ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា**
**និង ក្រសួងស្បៀងអាហារនៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដេស**

ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៧ វេលាម៉ោង ០២:៣០ នាទីរសៀល
នៅៈ សាលប្រជុំអង្គរវត្ត ក្រសួងពាណិជ្ជកម្ម

| **របៀបវារៈ** | | |
|---|---|---|
| 2:00 – 02:30 | • ពិធីចុះឈ្មោះភ្ញៀវកិត្តិយស<br>• ការអញ្ជើញមកដល់នៃគណៈប្រតិភូ | • ភ្ញៀវកិត្តិយស និងគណៈប្រតិភូ |
| 02:30 – 02:45 | • សុន្ទរកថាបើក រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា | • ឯកឧត្តម ប៉ាន សូរស័ក្តិ |
| 02:40 – 3:00 | • សុន្ទរកថាបើក រដ្ឋមន្ត្រីក្រសួងស្បៀងអាហារបង់ក្លាដេស | • H.E. Advocate Md. Qamrul Islam |
| 03:05 – 3:15 | • ពិធីចុះអនុស្សរណៈនៃយោគយល់គ្នា ស្តីពីការទិញអង្ករកម្ពុជាចំនួន ១លានតោន | • គណៈប្រតិភូនៃប្រទេសទាំងពីរ |
| 03:15 – 3:30 | សន្និសីទសារព័ត៌មាន | |

**កម្មវិធីនេះអាចប្រែប្រួលទៅតាមស្ថានភាពជាក់ស្តែង*